01575124

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ D314/2

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥៧)

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គីមសាន ជាប្រធាន
ចៅក្រម Oliver BEAUVALLET
ចៅក្រម ន៉ីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28/06/2018
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ:**

**សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំធ្វើចំណាត់ថ្នាក់ឡើងវិញ
នូវសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
Wayne JORDASH

01575125



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**"អ.វ.ត.ក"**) បានទទួល "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំធ្វើចំណាត់ថ្នាក់ឡើងវិញនូវសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)"[1] ដែលបានដាក់នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៨ ("សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ")

## I. **សេចក្តីផ្តើម**

១. សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈនូវ "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)"[2] និង "ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)"[3] ដោយមានការកោសលុបដូចគ្នាដូចដែលបានកំណត់ដោយអង្គបុរេជំនុំជម្រះ។

## II. **ប្រវត្តិនីតិវិធី និងសេចក្តីសង្ខេបសារណា**

២. នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៨ អង្គបុរេជំនុំជម្រះទទួលបានសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ[4]។ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈនូវ

---

[1] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤/១") សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំធ្វើចំណាត់ថ្នាក់ឡើងវិញនូវសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D314 ("សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ")។

[2] សំណុំរឿង ០០៤/១ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/1 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)")។

[3] សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/13 ("ការឆ្លើយតបទាក់ទងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)")។

[4] សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ។

បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) និងការឆ្លើយតបរបស់គាត់ទាក់ទងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) "ដើម្បីជាផលប្រយោជន៍យុត្តិធម៌ និងតម្លាភាព" ហើយខ្លឹមសារនៃសេចក្តីសន្និដ្ឋានបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ក៏ដូចជាឯកសារនានាដែលជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានបណ្តឹងឧទ្ធរណ៍ទាំងនេះស្ថិតនៅជាសាធារណៈរួចហើយ[5]។ សហព្រះរាជអាជ្ញាអះអាងទៀតថា ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) របស់សហព្រះរាជអាជ្ញា ក៏គួរតែធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈផងដែរ[6]។

៣. តាមរយៈលិខិតមួយចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ សហមេធាវីមិនជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំធ្វើចំណាត់ថ្នាក់ឡើងវិញនូវសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)[7]។

## III. អង្គសេចក្តី

៤. បានឃើញមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[8] និងមាត្រា ៩.១ នៃសេចក្តីណែនាំស្តីពីការធ្វើចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង[9]។

---

[5] សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ ៣។

[6] សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ ៤។ សូមមើល ផងដែរ សំណុំរឿង ០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/11 ។

[7] សំណុំរឿង ០០៤/១ លិខិតមានចំណងជើងថា "ចម្លើយតបទៅនឹងសំណើសហព្រះរាជអាជ្ញាអន្តរជាតិសុំធ្វើចំណាត់ថ្នាក់ឡើងវិញនូវសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)" ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D314/1។

[8] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨ មាត្រា ៣.១៤។

[9] សេចក្តីណែនាំស្តីពីការធ្វើចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី២ មាត្រា ៩.១ ("សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ")។

៥. ដោយពិចារណាទៅលើសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ)[10] ដែលបានចេញនៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨។

៦. ដោយពិចារណាទៅលើសេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[11] ដែលបានចេញក្នុងថ្ងៃដដែលនេះដែរ។

៧. រម្លឹកឡើងវិញថា គោលការណ៍ចាំបាច់នៃការធ្វើចំណាត់ប្រភេទ "គឺជាតម្រូវការទាមទារឱ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហរដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរដំណែល"[12]។

---

[10] សំណុំរឿង ០០៤/១ (អបជ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D309/2/1/7។

[11] សំណុំរឿង ០០៤/១ (អបជ៥៤) សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D304/6/4។

[12] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ មាត្រា ១.២។ សូមមើល ផងដែរ សំណុំរឿងលេខ ០០២ (អបជ៥៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១។ សំណុំរឿងលេខ ០០៤/១ (អបជ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D309/2/1/7 កថាខណ្ឌ ២៧។ សំណុំរឿងលេខ ០០៤/១ (អបជ៥៤) សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទ

៨. រម្លឹកឡើងវិញអំពីតម្រូវការក្នុងការធានានូវការការពារសាក្សី និងបញ្ជីឈ្មោះពាក់ព័ន្ធនៃបុគ្គលដែលទទួលបានការការពារ[13]។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

- **បង្គាប់** សហព្រះរាជអាជ្ញាអន្តរជាតិ ដាក់បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3/1/1) និងការឆ្លើយតបរបស់គាត់ទាក់ទងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3/1/13) ជាឯកសារសាធារណៈ ក្នុងរយៈពេលប្រាំថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

- **បង្គាប់** សហមេធាវី ដាក់ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3/1/11) ជាឯកសារសាធារណៈ ក្នុងរយៈពេលប្រាំថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

- **ណែនាំ** សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវី កោសលុបឈ្មោះ និងអាសយដ្ឋានបុគ្គលដែលទទួលបានវិធានការការពារ អនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង ឬដែលស្នើសុំវិធានការការពារ។

---

ឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D304/6/4 កថាខណ្ឌ ១៨។

[13] សូមមើល អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងឧបសម្ព័ន្ធ ឯកសារ D309/2/1/5/1.2 និងអនុស្សរណៈរបស់ ក.ស.ច.ស និងឧបសម្ព័ន្ធ ឯកសារ D309/2/1/6/1.2។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**